**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សភាពាណិជ្ជកម្មកម្ពុជា**
លេខ : ១៤២/១៦ សភពណ.កជ

# សារលិខិតជូនពរ

## ឯកឧត្តម ជា សុផារ៉ា
## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់
## ក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំវក សប្បស័ក ព.ស ២៥៦០

*ឯកឧត្តមទេសរដ្ឋមន្ត្រីជាទីគោរពដ៏ខ្ពង់ខ្ពស់ !*

នៅក្នុងឱកាសដ៏មហានក្ខត្តឫក្សសួស្តីប្រពៃថ្លៃថ្លា ប្រកបដោយមនោសញ្ចេតនាសោមនស្សរីករាយនៃឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំវក សប្បស័ក ព.ស ២៥៦០ តាងនាមថ្នាក់ដឹកនាំ និងសមាជិក-សមាជិកា នៃសភាពាណិជ្ជកម្មកម្ពុជា ខ្ញុំសូមសម្តែងនូវក្តីអំណរសាទរឥតឧបមា ចូលរួមជូននូវសព្ទសាធុការពរជ័យ បវរសួស្តី សេរីវឌ្ឍនា វិបុលសុខ មហាប្រសើរគ្រប់យ៉ាង និងសូមគោរពជូនពរ ***ឯកឧត្តមទេសរដ្ឋមន្ត្រី*** ប្រកបដោយសុខភាពល្អបរិបូណ៌ អាយុយឺនយូរ កាយពលរឹងមាំខ្លាំងក្លា បញ្ញាញាណភ្លឺថ្លាត្រចះត្រចង់ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍប្រទេសកម្ពុជា ឱ្យកាន់តែរីកចម្រើនជឿនលឿនថែមទៀត ក្រោមមាគ៌ាដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនា បតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ។

ឆ្លៀតនៅក្នុងឱកាសដ៏មហានក្ខត្តឫក្សសួស្តីប្រពៃថ្លៃថ្លាក្នុងឱកាសបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិឆ្នាំវក សប្បស័ក ព.ស ២៥៦០នេះផងដែរ យើងខ្ញុំទាំងអស់គ្នា ជាថ្នាក់ដឹកនាំ និងសមាជិក-សមាជិកា នៃសភាពាណិជ្ជកម្មកម្ពុជា ក៏សូមគោរពសម្តែងនូវសេចក្តីសោមនស្សរីករាយ ចូលរួមជូននូវសព្ទសាធុការពរជ័យគ្រប់ប្រការជូន ***ឯកឧត្តមទេសរដ្ឋមន្ត្រី*** និង លោកជំទាវ ព្រមទាំងបុត្រាបុត្រី បុត្រប្រសារ ចៅប្រុស ចៅស្រី ជាទីស្រឡាញ់ សូមបានប្រកបនូវពុទ្ធពរទាំងបួន ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ជានិច្ចនិរន្តរ៍ ។

សូម ***ឯកឧត្តមទេសរដ្ឋមន្ត្រី*** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ សេចក្តីស្រឡាញ់ដ៏ជ្រាលជ្រៅបំផុតអំពីយើងខ្ញុំទាំងអស់គ្នា ៕

*រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែមេសា ឆ្នាំ២០១៦*

**ប្រធានសភាពាណិជ្ជកម្មកម្ពុជា**

CAMBODIA CHAMBER OF COMMERCE

**គិត_ម៉េង**

ទីស្នាក់ការ : អាគារលេខ ៧D ផ្លូវសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ: (៨៥៥_២៣) ៨៨០ ៧៩៥ ទូរសារលេខ: (៨៥៥_២៣) ៨៨១ ៧៥៧ E-mail: ccc@ezecom.com.kh , info@ccc.org.kh, www.ccc.org.kh